**សញ្ជាតិ (Nationality)**

សញ្ជាតិ ជាទំនាក់ទំនងផ្លូវច្បាប់រវាងរដ្ឋ និងបុគ្គល មានមូលដ្ឋានពីហេតុការណ៍សង្គមនៃចំណងភ្ជាប់ទំនាក់ទំនងពិតប្រាកដ នៃអត្ថិភាពផលប្រយោជន៍ និងមនោសញ្ចេតនា រួមជាមួយនឹងសិទ្ធិព្រមទាំងករណីកិច្ចទៅវិញទៅមក។

ក្រៅពីបុគ្គល នីតិបុគ្គល ក៏អាចទទួលបានសញ្ជាតិដែរ។ មានសញ្ជាតិ នាំឲ្យមានការការពារផ្លូវទូតរបស់រដ្ឋក្នុងករណីមានការបំពានប្រយោជន៍ដល់ប្រជាពលរដ្ឋ ដោយអាជ្ញាធររដ្ឋផ្សេង (diplomatic protection) ហើយរដ្ឋក៏មានយុត្តាធិការលើ បុគ្គល ឬនីតិបុគ្គល ដែលមានសញ្ជាតិ ដែលប្រព្រឹត្តបទល្មើស (nationality principle) (EDIL, Nationality, pp. 403)។ សញ្ជាតិ ទទួលបាន តាមរយៈឈាមជ័រឪពុកម្ដាយ ឬ ទីកន្លែងកំណើត។ បន្ថែមពីលើនេះ បុគ្គលអាចទទួលបានសញ្ជាតិបរទេស តាមរយៈការរៀបអាពាហ៍ពិពាហ៍ ដែលត្រូវដាក់ពាក្យសុំដើម្បីបានសញ្ជាតិ (naturalization)( EDIL, p. 408)។

**<u>ខ្លឹមសារបន្ថែម</u>**៖ បុគ្គលអាចមានសញ្ជាតិ ១ ឬពីរ អាស្រ័យទៅតាមច្បាប់ជាតិចែងកំណត់។ កិច្ចការងារផ្ដល់សញ្ជាតិ ជាការងារផ្ទៃក្នុងរបស់រដ្ឋ វិធានច្បាប់អន្តរជាតិ ឬស្ថាប័នអន្តរជាតិ ជាទូទៅ មិនលូកលន់ក្នុងរឿងផ្ដល់សញ្ជាតិនេះទេ។ បុគ្គលមានសិទ្ធិ (ប្រធាននៃច្បាប់) មានឈ្មោះ និងសញ្ជាតិ ដែលត្រូវបានទទួលស្គាល់ជាមនុស្ស ទទួលបានការការពារតាមផ្លូវច្បាប់។ ដោយសារកត្តាសង្គម ឬច្បាប់ បានធ្វើឲ្យមនុស្សមួយចំនួន ក្លាយជាបុគ្គលគ្មានសញ្ជាតិ (stateless person)។